# វេឡុកជាតក




*ព្រះសាស្តាកាលស្តេចគង់នៅវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុប្រដៅក្រមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា* **យោ អត្ថកាមស្ស** *ដូច្នេះជាដើម ។*

*មានរឿងសង្ខេបថា ព្រះមានព្រះភាគត្រាស់សួរភិក្ខុនោះថា ម្នាលភិក្ខុ បានឮថា អ្នកប្រដៅក្រ ពិតមែនឬ? កាលភិក្ខុនោះទូលថា ព្រះករុណាព្រះអង្គ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន អ្នកក៏ជាមនុស្សប្រដៅក្រដែរ ព្រោះភាពជាមនុស្សប្រដៅក្រនោះឯង ទើបមិនធ្វើតាមពាក្យទូន្មានរបស់បណ្ឌិត ហើយត្រូវដល់ការអស់ជីវិតក្នុងមាត់ពស់ (ពស់ចឹកស្លាប់) ដូច្នេះហើយព្រះអង្គនាំយកអតីតនិទានមកថា ៖*

*ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិ ក្នុងនគរពារាណសី ព្រះពោធិសត្វបដិសន្ធិ ក្នុងត្រកូលដែលមានសម្បត្តិច្រើនក្នុងដែនកាសី លុះចម្រើនវ័យហើយ*

*ឃើញទោសក្នុងកាមគុណ និងឃើញអានិសង្ស ក្នុងការចេញបួស ទើបលះបង់កាមទាំងឡាយ ហើយចូលព្រៃហិមពាន្ត បួសជាឥសី ធ្វើកសិណបរិកម្ម ញ៉ាំងអភិញ្ញា ៥ និងសមាបត្តិ ៨ ឲ្យកើតហើយ នៅដោយសុខដែលកើតអំពីឈាន ក្រោយមកមានបរិវារច្រើន មានតាបស ៥០០ ចោមរោម ជាគ្រូនៃគណៈ ។*

*គ្រានោះ មានកូនអាសិរពិសមួយលូន ទៅតាមធម្មតារបស់វា ក៏ដល់អាស្រមបទរបស់តាបសមួយរូប ។ តាបសឃើញហើយកើតសេចក្ដីស្រឡាញ់អាសិរពិសនោះដូចជាកូន ក៏ចាប់វាយកមកចញ្ចឹម ដាក់ឲ្យដេកក្នុងបំពង់ឫស្សីមួយ ព្រោះហេតុតែអាសិរពិសនោះ ដេកក្នុងបំពង់ឫស្សី ទើបតាបសទាំងឡាយឲ្យវាឈ្មោះថា* ***វេឡុកៈ*** *ហើយព្រោះហេតុតែតាបសនោះ ចិញ្ចឹមអាសិរពិសនោះ ដោយសេចក្ដីស្រឡាញ់ដូចជាកូន ទើបតាបសទាំងឡាយដាក់ឈ្មោះឲ្យតាបសនោះថា* ***វេឡុកបិតា*** *។ ពេលនោះ ព្រះពោធិសត្វដឹងថា បានឮថា តាសបមួយរូបចញ្ចឹមអាសិរពិស ទើបហៅមកសួរថា បានឮថា អ្នកចិញ្ចឹមអាសិរពិសមែនឬ ? កាលតាសបនោះឆ្លើយថា ពិតមែនហើយ លោកក៏ដាស់តឿនថា ដែលឈ្មោះថា អាសិរពិសទុកចិត្តមិនបានទេ ដូច្នេះអ្នកកុំចញ្ចឹមវាអី ។*

*តាបសឆ្លើយតបថា បពិត្រអាចារ្យ វាដូចជាកូនរបស់ខ្ញុំ ខ្ញុំមិនអាចព្រាត់ប្រាស់វាបានទេ ។*

*ព្រះពោធិសត្វដាស់តឿនទៀតថា បើដូច្នេះ អ្នកនឹងដល់នូវសេចក្ដីស្លាប់ ព្រោះតែនៅជិតវាជាប្រាកដ ។*

*តាបសនោះមិនជឿពាក្យទូន្មាន របស់ព្រះពោធិសត្វ ហើយមិនដោះលែងអាសិរពិសនោះឡើយ ។*

*បន្ទាប់ពីពេលនោះ ពីរ-បីថ្ងៃប៉ុណ្ណោះ តាបសទាំងអស់នាំគ្នាទៅរកផលាផល លុះទៅដល់ហើយ ក៏ឃើញថា ផលាផលរកបានដោយងាយ ទើបសម្រាកនៅទីនោះពីរបីថ្ងៃ ។ ចំណែកតាបសវេឡុកបិតា កាលទៅជាមួយនឹងក្រុមតាបសទាំងនោះ ក៏ឲ្យអាសិរពិសដេកក្នុង*

*បំពង់ឫស្សីបិទទុកហើយទើបទៅ ។ កន្ទង់ទៅពីរបីថ្ងៃ ទើបត្រឡប់មកវិញជាមួយនឹងពួកតាបស រួចគិតថា អញនឹងឲ្យអាហារវេឡុកៈស៊ី បើកបំពង់ឫស្សីហើយនិយាយថា មកចុះកូនកូនឯងឃ្លានហើយឬ? និយាយបណ្ដើរលូកដៃចូលទៅបណ្ដើរ អាសិរពិសខឹងព្រោះអត់អាហារមកពីរបីថ្ងៃ ទើបចឹកដៃតាបសដែលលូកចូលទៅ ធ្វើឲ្យតាបសអស់ជីវិត នៅត្រង់នោះឯងហើយលូនចូលព្រៃបាត់ទៅ។ តាបសទាំងឡាយឃើញដូច្នេះ ក៏ប្រាប់ព្រះពោធិសត្វ ។ ព្រះមហាសត្វប្រាប់ឲ្យធ្វើសរីរកិច្ច របស់តាបសដែលអស់ជីវិតនោះ ហើយអង្គុយនៅកណ្ដាលតាបសពោលគាថានេះដោយអំណាចជាពាក្យទូន្មានតាបសទាំងនោះថា*

**យោ អត្ថកាមស្ស ហិតានុកម្បិនោ, ឱវជ្ជមានោ ន ករោតិ សាសនំ;**
**ឯវំ សោ និហតោ សេតិ, វេឡុកស្ស យថា បិតា។**

*បុគ្គលណា កាលលោកអ្នកប្រាថ្នាសេចក្ដីចម្រើន អនុគ្រោះដោយប្រយោជន៍ទូន្មាន មិនធ្វើតាមពាក្យប្រៀនប្រដៅ បុគ្គលនោះរមែងដេកស្លាប់ ដូចឥសីជាបិតានៃពស់ឈ្មោះវេឡុកៈ ។*

*ព្រះពោធិសត្វទូន្មានប្រៀនប្រដៅពួកឥសីយ៉ាងនេះហើយ ចម្រើនព្រហ្មវិហារទាំង ៤ ក្រោយអំពីអស់ជីវិត ក៏កើតក្នុងព្រហ្មលោក ។*

*ព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុ មិនមែនតែក្នុងកាលឥឡូវប៉ុណ្ណោះទេ ដែលអ្នកជាមនុស្សប្រដៅក្រនោះ សូម្បីក្នុងកាលមុន អ្នកក៏ជាមនុស្សប្រដៅក្រដែរ ព្រោះភាពជាមនុស្សប្រដៅក្រនោះឯង ទើបធ្វើឲ្យអ្នកដល់ភាពស្អុយក្នុងមាត់អាសិរពិស ។*

*ព្រះសាស្ដានាំព្រះធម្មទេសនានេះមកហើយ ទ្រង់បន្តអនុសន្ធិ និងប្រជុំជាតកថា*

**តទា វេឡុកបិតា ទុព្ពចភិក្ខុ អហោសិ** *តាបសវេឡុកបិតាក្នុងកាលនោះ បានមកជាភិក្ខុប្រដៅក្រនេះ*

**សេសបរិសា ពុទ្ធបរិសា** *បរិសទ័ដ៏សេស បានមកជាពុទ្ធបរិសទ័*

**គណសត្ថា បន អហមេវ អហោសិំ** *សាស្តាមេគណៈនៃឥសីគឺ តថាគតនេះឯង ។*

*វេឡុកជាតក ចប់ ៕*

*(ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក ឯកកនិបាត អត្ថកាមវគ្គ វេឡុកជាតក បិដកលេខ ៥៨ ទំព័រ ២០)*

*ដោយស.ដ.វ.ថ.*